

# តើនៅក្នុងឆ្នាំងជាអ្វីទៅ?

Crystal Warren

Hayley Alonzo





សេមសួរថា «មានអ្វីញ៉ាំល្ងាចនេះ?»។ ម៉ាក់តបថា «វាជាការភ្ញាក់ផ្អើល»ពេលដែលគាត់កំពុងដាក់ឆ្នាំងដ៏ធំមួយនៅលើចង្ក្រាន។



គាត់បានចាក់ទឹកមួយថូចូលទៅ។ សេមព្រួយចិត្តណាស់។ គេក៏ស្រែកសួរថា «ពួកយើងញ៉ាំទឹកសម្រាប់អាហារពេលល្ងាចមែនទេ?» ម៉ាក់ក៏តបថា «វាជាការភ្ញាក់ផ្អើល។ ចាំមើលសិនទៅ។»





សេមសួរថា «ខ្ញុំអាចជួយបានអត់? ខ្ញុំចេះកូរ។» ម៉ាក់ក៏និយាយថា «កូននៅទាបណាស់។ ឆ្នាំងអាចនឹងធ្លាក់ចុះមក។ ប៉ុន្តែ កូនអាចជួយយករបស់ឱ្យម៉ាក់បាន។»

 

«ជួយយកខ្ទឹមឱ្យម៉ាក់បន្តិចមក។» «របស់នេះមានក្លិនមិនល្អ
សោះ។» «ពេលវាឆ្អិន វានឹងមានរសជាតិឆ្ងាញ់។»



«ឥឡូវ ម៉ាក់ត្រូវការប៉េងប៉ោះ។» «អត់ទេ នោះគឺផ្លែប៉ោមទេតើ។
ប៉េងប៉ោះមានរាងមូល ហើយមានពណ៌ក្រហម កូនអាចរកវា
ឃើញនៅក្នុងទូរទឹកកក។»



«យកដំឡូងឱ្យម៉ាក់ផង។ វាមានរាងមូល ហើយមាន
ពណ៌ត្នោត។» «តើអាហារឆ្អិននៅ?»



«ក្នុងពេលរង់ចាំ បើឃ្លាន កូនញុាំផ្លែប៉ោមសិនទៅ។» «ចុះរបស់នេះ?» «អត់ទេ ពួកយើងអត់ទាន់ត្រូវការនំនេះទេ។ ពួកយើងទុកវាចាំ ពេលញុាំបាយហើយ។»



«តើនៅក្នុងឆ្នាំងជាអ្វីទៅ?» «វាជាការភ្ញាក់ផ្អើល។ ចាំមើលទៅ!»





«ហើយចុះរបស់នេះវិញ?» «នោះគឺផ្លែឪឡឹក។ វាធំពេកហើយដាក់ចូលឆ្នាំងមិនចុះទេ។» «កូនរកមើលស្ពៃឱ្យម៉ាក់ផង។ វាក៏មានពណ៌បៃតងដែរ។»



«យកនំប៉័ងមកផង។» «ទេ អត់ដាក់វាចូលឆ្នាំងទេ ដាក់នៅលើតុ។»



ម៉ាក់កាន់ឆ្នាំង រួចដើរទៅតុ ហើយចាប់ផ្ដើមរៀបចំដួសដាក់ចាន។ សេមសួរថា «នៅក្នុងឆ្នាំងជាអ្វី?»។



«ស៊ុប! អាហារដែលខ្ញុំចូលចិត្ត!»





Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
*What's In the Pot?*, Author: Crystal Warren. Illustrator: Hayley Alonzo. Published by Book Dash, © Book Dash. Released under CC BY 4.0.

This work is a modified version of the original story. © The Asia Foundation, 2018. Some rights reserved. Released under CC BY 4.0.

For full terms of use and attribution,
http://creativecommons.org/licenses/by/4.0/
Contributing translators: koll phann and Sodany Ouch